# សេចក្ដីថ្លែងការរួមរបស់អង្គការសង្គមស៊ីវិល

# ស្ដីពី

# សេចក្ដីស្នើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការការរៀបចំ
# និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតរៀបចំការបោះឆ្នោត
# និងច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

**ថ្ងៃទី ០៦ ខែមីនា ឆ្នាំ២០១៥៖** យើងអង្គការសង្គមស៊ីវិលក្នុងប្រទេសកម្ពុជាចំនួន៦០ មកពីបណ្ដាញអង្គការនានារួមមាន៖ អង្គការសមាជិកភាពសម្ព័ន្ធកំណែទម្រង់ការបោះឆ្នោត សហាជីព ផ្ទះសាមគ្គី បណ្ដាញយុវជន បណ្ដាញស្ត្រីនិងយេនឌ័រ អង្គការសិទ្ធិមនុស្ស និង អង្គការអភិវឌ្ឍន៍នានាក្នុងប្រទេសកម្ពុជាមានការព្រួយបារម្ភចំពោះដំណើរការនៃរៀបចំសេចក្ដី ព្រាងច្បាប់ គុណភាពច្បាប់ និងបញ្ញត្តិទាំងឡាយដែលចែងក្នុងសេចក្ដីព្រាងច្បាប់ស្ដីពី ការរៀបចំនិងប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងសេចក្ដីស្នើពង្រាង ច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។

ក្នុងនាមអង្គការការពារសិទ្ធិមនុស្សសេរីភាពប្រជាធិបតេយ្យការអភិវឌ្ឍន៍សេដ្ឋកិច្ច និង សង្គមក្នុងប្រទេសកម្ពុជាទាំងអស់និងដើម្បីអនុវត្តកំណែទម្រង់ឲ្យមានភាពប្រាកដប្រជា និង មានអត្ថន័យពេញលេញ យើងទាមទារដាច់ខាតឲ្យគណបក្សនយោបាយជាប់ឆ្នោតទាំងពីរ និងភាគីដែលពាក់ព័ន្ធទាំងអស់ត្រូវអនុវត្តអនុសាសន៍ និងលក្ខណ្ឌដូចខាងក្រោម៖

- *ផ្ដល់នូវសំណៅឯកសារផ្លូវការស្ដីពីសេចក្ដីព្រាងច្បាប់ទាំងពីរដល់សាធារណៈជន និង បង្កើតបរិយាកាសនៃកិច្ចពិភាក្សាពិគ្រោះយោបល់ប្រកបដោយអត្ថន័យពេញលេញនិង មានតម្លាភាពជាមួយភាគីដែលពាក់ព័ន្ធទាំងអស់ និងធានាថា ការចូលរួមរបស់ស្ត្រី ក្នុងតួនាទីនៃសេចក្ដីសម្រេចចិត្តក្នុងរចនាសម្ព័ន្ធទាំងអស់ កើតចេញពីច្បាប់ស្ដីពីការរៀប ចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតនិងច្បាប់ស្ដីពី ការបោះឆ្នោតជ្រើសតាំងតំណារស្ត្រ។*

- *លុបចោលនូវបញ្ញត្តិទាំងឡាយដែលមានចែងក្នុងមាត្រា ៨៤, ១៣៧, ១៤៧ និងមាត្រា ១៥៨ នៃពង្រាងច្បាប់[1] ដែលបញ្ញត្តិទាំងនេះបានដកហូតសិទ្ធិនយោបាយនិងសិទ្ធិនៃការបញ្ចេញមតិរបស់អង្គការសង្គមស៊ីវិល។ ការដកហូតសិទ្ធិនយោបាយនិងសិទ្ធិបញ្ចេញមតិគឺពិតជាបានរំលោភរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជានិងសន្ធិសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយយ៉ាងពិតប្រាកដ។*

- *អនុវត្តឲ្យបានពេញលេញនូវបញ្ញត្តិនៃមាត្រា១៥ នៃច្បាប់ស្តីពីគណបក្សនយោបាយ ដើម្បីធានានូវអព្យាក្រិត្យភាពភាព ឥតលម្អៀងនៃកងកំលាំងប្រដាប់អាវុធ មន្ត្រីនគរបាលជាតិ និងមន្ត្រីតុលាការ។*

ជាមួយគ្នានេះផងដែរ យើងលើកទឹកចិត្តឲ្យប្រជាពលរដ្ឋចូលរួមនៅក្នុងការពិភាក្សាលើសេចក្តីព្រាងច្បាប់ទាំងនេះ និងលើកឡើងពីកង្វល់របស់ពួកគេទៅដល់អ្នកតំណាងរាស្ត្រ។

សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទងៈ

| **ឈ្មោះ** | **អង្គការ** | **លេខទូរស័ព្ទ** |
|---|---|---|
| • លោកស្រី ធីតា ឃឹះ | SILAKA | ០១២ ៨៣៨ ៤៦៤ |
| • លោក ធន សារាយ | ADHOC | ០១៦ ៤៤០ ០៤៤ |
| • លោក គល់ បញ្ញា | COMFREL | ០១២ ៩៤២ ០១៧ |
| • លោក សឿង សារឿន | CCC | ០១៦ ៩០០ ៥០៣ |
| • លោក ព្រាប កុល | TIC | ០១២ ៨៧៧ ៨៣៣ |
| • លោក តឹក វណ្ណារ៉ា | NGO Forum | ០១២៧៩៣ ៤៨៩ |

[1] សេចក្តីព្រាងច្បាប់មិនផ្លូវការ